**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Logo

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ............... ន.គ.ស...........

ថ្ងៃចន្ទ ៩រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមេស.គ.ស.២០២៥

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការស្នើសុំពន្យារពេលសម្រាប់ការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មកនិយ័តករគណនេយ្យនិងសវនកម្ម សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ**

**និយ័តករគណនេយ្យនិងសវនកម្ម** (**ន.គ.ស.**) **នៃ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**)

សូមជម្រាបជូន លោក លោកស្រី ជាម្ចាស់សហគ្រាសនឹងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ (អង្គភាព) មិនរងសវនកម្មឯករាជ្យ ជ្រាបថា៖ យោងសេចក្តីជូនដំណឹងលេខ ០៦៥/២៤ ន.គ.ស.ស.ជ.ណ.ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មក(**ន.គ.ស.**) តាមប្រព័ន្ធអនឡាញ (E-Filing System), កាលបរិច្ឆេទនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ ត្រូវបានផុតកំណត់កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៥ កន្លងទៅនេះ។ រហូតមកដល់ពេលនេះ មានសហគ្រាស និងអង្គភាព ជាច្រើនបានអនុវត្តការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ ប្រកបដោយជោគជ័យ និងទាន់ពេលវេលា ប៉ុន្តែក៏មានសហគ្រាសនិងអង្គភាពមួយចំនួន មិនបានអនុវត្តកាតព្វកិច្ចខាងលើ ទាន់ពេលវេលាកំណត់នៅឡើយ។

ដូច្នេះ ដើម្បីសម្រួលដល់សហគ្រាស និងអង្គភាព មិនរងសវនកម្មឯករាជ្យ ដែលមិនអាចបញ្ចប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ និងដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុនេះ មក **ន.គ.ស** តាមប្រព័ន្ធអនឡាញ (E-Filing System) តាមពេលកំណត់, **ន.គ.ស** សម្រេចអនុញ្ញាតដល់សហគ្រាស និងអង្គភាព មិនរងសវនកម្មឯករាជ្យ ដាក់លិខិតស្នើសុំ ពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មក **ន.គ.ស** និងស្នើសុំដាក់បញ្ជូនរបាយ ការណ៍ហិរញ្ញវត្ថុ មក **ន.គ.ស** ចំនួន៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ ដោយត្រូវអនុវត្តដូចខាងក្រោម៖

១.- សហគ្រាស និងអង្គភាព មិនរងសវនកម្មឯករាជ្យ ត្រូវដាក់លិខិតស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងារ រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មក **ន.គ.ស** ដោយផ្ទាល់ មិនឱ្យហួសថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥។

- ដោយឡែកសហគ្រាស និងអង្គភាព មិនរងសវនកម្មឯករាជ្យ ដែលត្រូវបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុស ពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់លិខិតស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងាររៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មក **ន.គ.ស** និងស្នើសុំដាក់

បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស** ចំនួន៣០ (សាមសិប)ថ្ងៃ ប៉ុន្តែ មិនឱ្យហួសរយៈពេល៤ខែ បូក២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

២. សហគ្រាស និងអង្គភាព មិនរងសវនកម្មឯករាជ្យ ត្រូវបង់កម្រៃលើសេវាស្នើសុំពន្យារពេលក្នុងការបញ្ចប់ការងារ រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ អនុលោមតាម ប្រកាសលេខ០០២ អ.ស.ហ. ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

<u>ការខកខានមិនដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មក **ន.គ.ស** ជាកម្មវត្ថុនៃការអនុវត្តវិធានការ តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។</u>

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមន្ត្រី **ន.គ.ស** តាមរយៈលេខទូរស័ព្ទ និងតេឡេក្រាមដូចខាងក្រោម÷

១. សម្រាប់សហគ្រាស ÷ ០៩២ ៩១៩ ១៩២/ ០៩៩ ៤២៩ ៣៩៨/ ០៧០ ៥៤៥ ៦៨៨/ ០៧០ ២១២ ២៣៦/ ០៦៩ ៥១៩ ៣៧១

២. សម្រាប់អង្គភាព ÷ ០៨១ ៦៤៤ ៦៦៣/ ០៩២ ៦៨៨ ២៩៧/ ០៨៥ ៩០៤ ៨៤៨/ ០៨៥ ៤៤៤ ៤៨៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel
របស់និយ័តករគណនេយ្យនិងសវនកម្ម

Phnom Penh, April 21, 2025

**Notification**

**On**

**Request for deadline extension for the preparation of annual financial statements 2024 and submission of annual financial statements 2024 to the Accounting and Auditing Regulators for non-audited enterprises and non-profit organizations.**

Accounting and Auditing Regulator of the Non-Banking and Financial Services Authority.

In order to facilitate the non-audited enterprises and non-profit organizations that cannot complete the preparation of the financial statements for 2024 and submit this financial statement to the ACAR through the E-Filing System at the due time, the ACAR decides to allow the non-audited enterprises and NGOs submit a requesting letter for the extension of the preparation of the annual financial states for 2024 and request for the submission in thirty (30) days counting from April 21, 2025 to May 20, 2025 with the following implementation:

1. Non-audited enterprises and NGOs shall submit an extension requesting letter of the annual financial Statement by May 20, 2025.

In particular, non-audited enterprises and NGOs that are allowed to close the accounting year ended other than December 31 shall submit an extension requesting letter of the annual financial statements for the year 2024 to ACAR in thirty (30) days, but not more than four (4) months, plus twenty (20) days from the year ended.

2. Non-audited enterprises and NGOs shall pay a service fee for the extension request for the completion of the annual financial statements in accordance with Prakas No. 002. dated 15 January 2025 on Public Services of the Accounting and Auditing Regulators.

Failure to submit the annual financial statements for the year 2024 to the ACAR is subject to the implementation of legal regulations in force.

***Accounting And Auditing Regulator***